39

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៨ អនក្រ.បក

ចូល ថ្ងៃទី 24 ខែ 10 ឆ្នាំ 1996

1549

## អនុក្រឹត្យ

## ស្តីពីការកំណត់របបម៉ោងកំណត់ ម៉ោងបន្ថែម និង ប្រាក់ម៉ោងបន្ថែម

## សំរាប់ការបង្រៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈ

*********************

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស_រកត_១០៩៤_៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស_រកត_១០៩៤_៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស_រកម_០១៩៦_០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសេចក្តីសំរេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ៧៧ សសរ ចុះថ្ងៃទី២០ ខែ សីហា ឆ្នាំ ១៩៨៣ ស្តីពីការកំណត់ប្រាក់កំរៃម៉ោងបន្ថែមសំរាប់កម្មាភិបាល បុគ្គលិក គ្រូបង្រៀន និង សាស្ត្រាចារ្យ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ ចុះថ្ងៃទី ១១ ខែ មិនា ឆ្នាំ ១៩៩២ ស្តីពីការកែលំអរបៀបត្រួតកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

តាមការយល់ព្រមនៃគណៈរដ្ឋមន្ត្រី

### សំរេច

មាត្រា ១ : ដែលហៅថាម៉ោងកំណត់ គឺជារយៈពេលគិតជាម៉ោងក្នុងមួយសប្តាហ៍ ដែលគ្រូបង្រៀន និង សាស្ត្រាចារ្យ មានភារកិច្ចបង្រៀន និង បំពេញការងារគរុកោសល្យនៅក្នុងគ្រឹះស្ថានសិក្សា ។

_ ដែលហៅថាម៉ោងបន្ថែម គឺជារយៈពេលគិតជាម៉ោង ដែលគ្រូបង្រៀន និង សាស្ត្រាចារ្យបានបង្រៀន និង បំពេញការងារតុកោសល្យ លើសពីម៉ោងកំណត់ ។

**មាត្រា ២** : _ អំពីចំនួនម៉ោងកំណត់ប្រចាំសប្តាហ៍ :

ក/ ចំពោះគ្រូបង្រៀន និង សាស្ត្រាចារ្យ ដែលមានមុខងារ និង ឋានៈត្រូវនឹងកំរិតសិក្សាដែលបង្រៀន មានកំណត់ក្នុងតារាងខាងក្រោម ÷

| គ្រឹះស្ថានសិក្សា ឬ ថ្នាក់បណ្តុះបណ្តាល | ចំនួនម៉ោងបង្រៀនទ្រឹស្តីប្រចាំសប្តាហ៍ | ចំនួនម៉ោងណែនាំអនុវត្ត រៀបចំការងារបង្រៀន កំណែប្រចាំសប្តាហ៍ |
|---|---|---|
| * ផ្នែកចំណេះទូទៅ | | |
| _ អនុវិទ្យាល័យ | ១៨ ម៉ោង | ២០ ម៉ោង |
| _ វិទ្យាល័យ | ១៦ ម៉ោង | ១៨ ម៉ោង |
| * ផ្នែកមុខជំនាញ | | |
| _ បណ្តុះបណ្តាលវិជ្ជាជីវៈ | ១៦ ម៉ោង | ១៨ ម៉ោង |
| _ មធ្យមសិក្សាបច្ចេកទេស | ១៤ ម៉ោង | ១៨ ម៉ោង |
| _ ឧត្តមសិក្សា | ១២ ម៉ោង | ១៦ ម៉ោង |
| _ ក្រោយឧត្តមសិក្សា | ១០ ម៉ោង | ១៤ ម៉ោង |
| * ថ្នាក់បណ្តុះបណ្តាលរយៈពេលខ្លី | | |
| _ ថ្នាក់កំរិតពាក់កណ្តាលមធ្យម | ១៦ ម៉ោង | ១ ម៉ោង ទ្រឹស្តីស្មើនឹង ២ ម៉ោងពិភាក្សា |
| _ ថ្នាក់កំរិតមធ្យម | ១៤ ម៉ោង | សំណួរ ឬ អនុវត្តជាក់ស្តែង |
| * ថ្នាក់កំរិតកែកការ | | |
| _ ថ្នាក់កំរិតពាក់កណ្តាលមធ្យម | ១៦ ម៉ោង | ១ ម៉ោង ទ្រឹស្តីស្មើនឹង ២ ម៉ោងពិភាក្សា |
| _ ថ្នាក់កំរិតមធ្យម | ១៤ ម៉ោង | សំណួរ ឬ អនុវត្តជាក់ស្តែង |

ខ/ _ សាស្ត្រាចារ្យ គ្រូបង្រៀន ដែលមានក្របខ័ណ្ឌខ្ពស់ ហើយទៅបង្រៀននៅគ្រឹះស្ថានសិក្សាទាប ត្រូវអនុវត្តរបបម៉ោងកំណត់ទៅតាមក្របខ័ណ្ឌរបស់ខ្លួន ។

_ សាស្ត្រាចារ្យ គ្រូបង្រៀន ដែលមានក្របខ័ណ្ឌទាប ហើយទៅបង្រៀននៅគ្រឹះស្ថានសិក្សាខ្ពស់ ត្រូវអនុវត្តរបបម៉ោងកំណត់ទៅតាមកំរិតគ្រឹះស្ថានសិក្សានោះ ។

_ ក្របខ័ណ្ឌបច្ចេកទេស ដែលមានភារកិច្ចជួយរៀបចំ និង ធ្វើការនៅតាមទីពិសោធន៍ រោងជាងសិក្សា ត្រូវបំពេញភារកិច្ចប្រចាំសប្តាហ៍ តាមការកំណត់ដូចខាងក្រោម :

_ កម្មករមន្ទីរពិសោធន៍ និង រោងជាងសិក្សា ៣៦ ម៉ោង

_ បរិវច្ឆេការី ត្រូវអនុវត្តនៅមន្ទីរពិសោធន៍ និង រោងជាងសិក្សា ៣០ ម៉ោង

**មាត្រា ៣** ៖ អ្នកដែលមានភារកិច្ចបង្រៀនជារបបម៉ោងបន្ថែម ត្រូវកំណត់យ៉ាងច្រើនបំផុត ៤៨ ម៉ោង ក្នុងមួយខែ ។

_ មន្ត្រីរាជការស៊ីវិលអាចបង្រៀនម៉ោងបន្ថែមជាអតិបរមាចំនួន ៣២ ម៉ោង ក្នុងមួយខែ ។

**មាត្រា ៤ :** _ អំពីប្រាក់ម៉ោងបន្ថែម :

ក) សាស្ត្រាចារ្យ គ្រូបង្រៀន ដែលបានបង្រៀនលើសពីចំនួនម៉ោងកំណត់ ដូចក្នុងប្រការ ២ ត្រូវបានទទួលប្រាក់កំរៃម៉ោងបន្ថែម ក្នុងមួយម៉ោងមានតំលៃដូចក្នុងតារាងខាងក្រោម ÷

| កំរិតសិក្សា / សញ្ញាប័ត្រ ឬ ក្របខ័ណ្ឌ | _ មធ្យមសិក្សាបច្ចេកទេស<br>_ បណ្តុះបណ្តាលវិជ្ជាជីវៈ<br>_ វិទ្យាល័យ<br>_ អនុវិទ្យាល័យ | ឧត្តមសិក្សា | ក្រោយឧត្តមសិក្សា |
|---|---|---|---|
| សាស្ត្រាចារ្យថ្នាក់អនុបណ្ឌិត ឬ ខ ៤ ឡើងទៅ | | ៩.៣០០ ៛<br>"ប្រាំបួនពាន់បីរយរៀល" | ១០.៤០០ ៛<br>"ដប់ពាន់បួនរយរៀល" |
| សញ្ញាប័ត្រឧត្តមសិក្សា ក្របខ័ណ្ឌ ខ ។ | ៥.២០០ ៛<br>"ប្រាំពាន់ពីររយរៀល" | ៧.៨០០ ៛<br>"ប្រាំពីរពាន់ប្រាំបីរយរៀល" | |
| សញ្ញាប័ត្រមធ្យមសិក្សា ក្របខ័ណ្ឌ ខ ॥ | ២.៦០០ ៛<br>"ពីរពាន់ប្រាំមួយរយរៀល" | ២.៦០០ ៛<br>"ពីរពាន់ប្រាំមួយរយរៀល" | |
| ប្រភេទ ខ ॥। គ ។ ឬ គ ॥ | ២.០០០ ៛<br>"ពីរពាន់រៀល" | ២.០០០ ៛<br>"ពីរពាន់រៀល" | |

ខ) _ ករណីពិសេស :

_ ចំពោះមន្ត្រីរាជការ ដែលបានចាត់តាំងជាផ្លូវការ អោយទៅបង្រៀនជាគ្រូជំនួយនៅសាលាមធ្យមសិក្សាឯកទេស សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ គ្រឹះស្ថានឧត្តមសិក្សា និង គ្រឹះស្ថានសិក្សាផ្សេងៗរបស់រដ្ឋ ត្រូវអនុវត្តរបបម៉ោងបន្ថែម ដោយគិតជាទឹកប្រាក់ម៉ោងបន្ថែមទៅតាមសញ្ញាប័ត្រ ឬ ក្របខ័ណ្ឌរបស់សាមីជន ។

_ ចំពោះមន្ត្រីរាជការ ដែលមានតួនាទី ចាប់ពីអនុប្រធាននាយកដ្ឋានឡើងទៅ និង ដែលបានចាត់តាំងជាផ្លូវការអោយទៅបង្រៀន ឬ ធ្វើជាគ្រូជំនួយ ហើយមានបៀវត្សក្នុងតារាង "ក" ។ "ខ" តែសាមីខ្លួនពុំមានសញ្ញាប័ត្រស្មើ ឬ ខ្ពស់ជាងសញ្ញាប័ត្រឧត្តមសិក្សាទេនោះ ត្រូវគិតប្រាក់ម៉ោងបន្ថែមដូចគ្រូបង្រៀនក្នុងប្រភេទ ខ ។ ។

_ ចំពោះអ្នកឯកទេសផ្សេងៗ មិនមែនជាមន្ត្រីរាជការ ដែលត្រូវអញ្ជើញមកអោយបង្រៀន ត្រូវស្នើសុំទៅក្រសួងតាមឋានានុក្រម ដើម្បីចេញលិខិតឧទ្ទេសនាម ដោយមានភ្ជាប់ច្បាប់ចំលងសញ្ញាប័ត្រ ឬ សំណុំលិខិតផ្សេងៗ ។ ការគិតប្រាក់ម៉ោងបន្ថែម ត្រូវគិតតាមសញ្ញាប័ត្រ និង កំរិតភូមិសិក្សា ដែលសាមីជនបានបង្រៀន ។

**មាត្រា ៥** : _ អនុក្រឹត្យនេះ អនុវត្តចំពោះតែមធ្យមសិក្សាចំណេះទូទៅ បណ្តុះបណ្តាលវិជ្ជាជីវៈ មធ្យមសិក្សាឯកទេស និង ឧត្តមសិក្សា ។ ចំពោះបឋមសិក្សានឹងមានកំណត់ក្នុងអនុក្រឹត្យដោយឡែក ។

**មាត្រា ៦** : _ បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៧** : _ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងពាក់ព័ន្ធ និង អភិបាលខេត្ត_ក្រុងទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៨** : _ អនុក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៦ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ១៩៩៦

នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២

នរោត្តម រណឫទ្ធិ | ហ៊ុន សែន

កន្លែងទទួល :

_ អគ្គលេខាធិការដ្ឋានរដ្ឋសភា
_ ខុទ្ទកាល័យព្រះមហាក្សត្រ
_ ខុទ្ទកាល័យសម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី១
_ ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២
_ គ្រប់ក្រសួង ស្ថាប័ន
_ ដូចមាត្រា ៧
_ កាលប្បវត្តិ _ ឯកសារ

---

ទីស្តីការក្រសួងសុខាភិបាល
លេខ ៥៧៤ ក.ស.ប

បានចម្លងជូនត្រឹមត្រូវ តាមច្បាប់ដើមនិងបញ្ជូនមកគ្រប់អង្គភាពក្រោមឱវាទក្រសួង ដាក់ពង្រាយដើម្បីផ្សព្វផ្សាយ និង អនុវត្តន៍ ។

ភ្នំពេញ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៩៦

ក.ស.រដ្ឋមន្ត្រី
ប្រធានខុទ្ទកាល័យ

វេជ្ជ.[illegible]